# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

សំណុំរឿងព្រហ្មទណ្ឌលេខ:៨០៧

ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ២០ (ច)

ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៨

## តាងនាមប្រជារាស្ត្រខ្មែរ

*សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការ*

ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៨

*ដោយមានសមាសភាពជំនុំជម្រះ៖*

១-លោក [redacted] *ចៅក្រមជំនុំជម្រះ*

២-លោកស្រី [redacted] *តំណាងអយ្យការ*

៣-លោក [redacted] *ក្រឡាបញ្ជីសវនាការ*

*<u>ដើម្បីធ្វើការជំនុំជម្រះលើជនជាប់ចោទ:</u>*

១-ឈ្មោះ[redacted] ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើតភូមិអំពិលក្លា ឃុំវាលពន់ ស្រុកថ្ពង់ ខេត្តកំពង់ស្ពឺ ទីកន្លែងសព្វថ្ងៃនៅភូមិអំពិលក្លា ឃុំវាលពន់ ស្រុកថ្ពង់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted](រ) នៅលីវ ទោសពីមុនគ្មាន (ឃុំខ្លួនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៧) ។

២-ឈ្មោះ [redacted]ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតភូមិអំពិលក្លា ឃុំវាលពន់ ស្រុកថ្ពង់ ខេត្តកំពង់ស្ពឺ ទីកន្លែងសព្វថ្ងៃនៅភូមិអំពិលក្លា ឃុំវាលពន់ ស្រុកថ្ពង់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន (ឃុំខ្លួនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៧) ។

៣-ឈ្មោះ[redacted](ហៀក) ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតភូមិអំពិលក្លា ឃុំវាលពន់ ស្រុកថ្ពង់ ខេត្តកំពង់ស្ពឺ ទីកន្លែងសព្វថ្ងៃនៅភូមិអំពិលក្លា ឃុំវាលពន់ ស្រុកថ្ពង់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន ។

ត្រូវជាប់ចោទពីបទ:*រក្សាទុក ផ្គត់ផ្គង់ដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅភូមិត្រពាំងម្ទេស ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ;**



Scanned by CamScanner

កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៧ វេលាម៉ោង ២០ និង១៥នាទី នៅចំណុចស្ពានកំពង់ក្តារ ព្រំប្រទល់ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង ក្នុងភូមិត្រពាំងម្ទេស ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង មានករណី រក្សាទុក ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលបង្កឡើងដោយឈ្មោ[redacted]ឈ្មោះ [redacted] និងឈ្មោះ [redacted]ជាអ្នកចែកចាយថ្នាំញៀន យ៉ាងសកម្មក្នុងខេត្តកំពង់ឆ្នាំង ក្នុងពេលសមត្ថកិច្ចធ្វើការបង្ក្រាប់នោះឈ្មោះ[redacted]បានបោះថ្នាំញៀនចូលក្នុងទឹកស្ទឹងបាត់ និងដកហូតបានម៉ូតូចំនួន ០១គ្រឿង។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ២៨៣៧ /១៧ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៦៣៦ /១៧ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ១៨៥៧ /១៧ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១៧ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយថា: អវត្តមាននាពេលសវនាការ ។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៧ ខ្លួនមានគ្នាចំនួនបីនាក់គឺរូបខ្លួន ឈ្មោះ [redacted]និងឈ្មោះ[redacted]ដោយពេលនោះខ្លួនកំពុងតែទិញថ្នាំញៀនពីឈ្មោះ[redacted] ក្នុងតម្លៃ ៣០.០០០(សាមសិបពាន់) រៀល ដើម្បីយកមកជក់តែប៉ុណ្ណោះ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនចំនួន ២០ ដងកន្លងមកហើយ ។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃកើតហេតុ ខ្លួនមានគ្នាពីរនាក់ដោយមានឈ្មោះ [redacted] និងឈ្មោះ[redacted]ដោយថ្នាំញៀនចំនួន ៣០.០០០(សាមសិបពាន់)រៀល ក្នុងនោះខ្លួនមានចំនួន ២០.០០០(ម្ភៃពាន់) រៀល ឈ្មោះ[redacted]ជួយចេញ ១០.០០០(ដប់ពាន់) រៀល ទិញពីឈ្មោះ [redacted] ដោយឈ្មោះ [redacted]ទៅទិញ។

-ចម្លើយមន្ត្រីនគរបាលឈ្មោះ[redacted]បានឆ្លើយថា: កាលពីថ្ងៃកើតហេតុ កម្លាំងនគរបាលស្រុកសាមគ្គីមានជ័យ ចុះល្បាតឃើញមានឈ្មោះ[redacted]ឈ្មោះ [redacted] និងឈ្មោះ [redacted]ដោយពេលនោះទៅប្រតិបត្តិការ ឃើញឈ្មោះ [redacted]កម្លាំងដេញចាប់ឃើញឈ្មោះ [redacted]បោះកាបូបគ្រឿងញៀននៅក្នុងស្ទឹង ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ឈ្មោះ [redacted]និងឈ្មោះ[redacted]ពីបទ *រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន* បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ។



Scanned by CamScanner

-ជនជាប់ចោទឈ្មោះ [redacted] បានសំណូមពរចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយ ទោសដល់រូបខ្លួនផង ។

-ជនជាប់ចោទឈ្មោះ: [redacted] បានសំណូមពរចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាដំបូងខេត្តកំពង់ឆ្នាំង យល់ឃើញថា:</u>

១-តុលាការបានទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៦៣៦ /១៧ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានបញ្ជូនជនជាប់ចោទ ១-ឈ្មោះ: [redacted] ២-ឈ្មោះ: [redacted] ៣-ឈ្មោះ [redacted] មកតុលាការដើម្បីជំនុំជម្រះពីបទ *រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅភូមិត្រពាំងម្ទេស ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ចម្លើយជនជាប់ចោទឈ្មោះ: [redacted] ថា: កាលពីថ្ងៃកើតហេតុ ខ្លួនមានគ្នាពីរនាក់បានទិញគ្រឿងញៀនពីឈ្មោះ: [redacted] ដើម្បីជក់តែប៉ុណ្ណោះ ដោយគ្រឿងញៀនមួយកញ្ចប់តម្លៃ ៣០.០០០(សាមសិបពាន់)រៀល ។

៣-ចម្លើយជនជាប់ចោទឈ្មោះ: [redacted] ថា: កាលពីថ្ងៃកើតហេតុ ខ្លួនមានគ្នាពីរនាក់ ដោយឈ្មោះ: [redacted] ទៅទិញគ្រឿងញៀនពីឈ្មោះ: [redacted] តម្លៃ ៣០.០០០(សាមសិបពាន់)រៀល ដើម្បីទៅជក់តែប៉ុណ្ណោះ ។

៤-ចម្លើយជនជាប់ចោទឈ្មោះ: [redacted] ថា: អវត្តមាននាពេលសវនាការ ។

៥-ចម្លើយមន្ត្រីនគរបាលថា: កាលពីថ្ងៃកើតហេតុ កម្លាំងខ្លួនឃើញមានឈ្មោះ: [redacted] ពេលប្រតិបត្តិការឃើញឈ្មោះ: [redacted] បោះចោលកាបូបដែលមានគ្រឿងញៀនចូលទៅក្នុងស្ទឹង ។

៦-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ: [redacted] .ឈ្មោះ: [redacted] និងឈ្មោះ [redacted] ពីបទ *រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន* បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ការប្តឹងសុំរបស់តំណាងអយ្យការ តុលាការអាចពិចារណាបានព្រោះបើតាមអង្គហេតុទោះបីជាជនជាប់ចោទព្យាយាមបដិសេធ ប៉ុន្តែពេលថ្ងៃកើតហេតុជនជាប់ចោទមានទំនាក់ទំនងទិញ



Scanned by CamScanner

គ្រឿងញៀនពីឈ្មោះ [redacted] ដែលជាមុខសញ្ញាជួញដូរគ្រឿងញៀន គួបផ្សំពេលប្រតិបត្តិការសមត្ថកិច្ចឃើញឈ្មោះ [redacted] បោះគ្រឿងញៀនទៅក្នុងទឹកផងដែរ ដូច្នេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៧-ឆ្លងកាត់សវនាការ ការពិភាក្សាដេញដោល ចម្លើយជនជាប់ចោទ ចម្លើយមន្ត្រីជំនាញ ការប្តឹងសុំរបស់តំណាងអយ្យការ ព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿងតុលាការពិចារណាឃើញថាជនជាប់ចោទទាំងបីពិតជាបានរក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ព្រោះទោះបីជាជនជាប់ចោទព្យាយាមបដិសេធ ប៉ុន្តែពេលប្រតិបត្តិការសមត្ថកិច្ចឃើញមានឈ្មោះ [redacted] បោះចោលកាបូបគ្រឿងញៀនទៅក្នុងស្ទឹង ទោះបីជាមិនបានដកហូតបានគ្រឿងញៀនក៏ដោយ មិនតែប៉ុណ្ណោះជនជាប់ចោទមានទំនាក់ទំនងជាមួយនឹងជនជាប់ចោទឈ្មោះ [redacted] ដែលជាអ្នកជួញដូរគ្រឿងញៀន ដូច្នេះគប្បីតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៧-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទ:

៧.១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២០ ឆ្នាំ ។

៧.២-ឈ្មោះ [redacted] ភេទប្រុស អាយុ ២០ ឆ្នាំ ។

៧.៣-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ឆ្នាំ ។

ពីបទ:*រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅភូមិត្រពាំងម្ទេស ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-វត្ថុតាងរួមមាន:

-ម៉ូតូចំនួន ០១ គ្រឿង ម៉ាកស៊ីភីអរ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ ១ស៊ុខេ ៨៥៧០ លេខម៉ាស៊ីនអរស៊ុី ១៧៨ អ៊ី ០៣០៨២៩១ លេខតួ អិលអេចខេស៊ុី ១៧៨៩០៥៣០៨២៩១ គប្បីតុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

៩-ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ១២៩/២០១៧ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៧ លើជនជាប់ចោទឈ្មោះ [redacted] បានអស់អានុភាពនៅដំណាក់កាលជំនុំជម្រះ គប្បីចៅក្រមជំនុំជម្រះចេញដីកាបង្គាប់ឲ្យចាប់ខ្លួនសារជាថ្មី ។

១០-ជនជាប់ចោទជានីតិជន ដែលមិនមានភស្តុតាងបញ្ជាក់ថាកើតមានវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ បំផ្លាញដល់សុខភាពខ្លួនឯងផ្ទាល់ ប៉ះពាល់ដល់ជីវភាពគ្រួសារ និងឈានដល់ការបង្កការលំបាកជាច្រើនទៀតដល់សង្គមជាតិ ដែលកើតឡើងដោយសារធាតុឥទ្ធិពលនៃគ្រឿងញៀន ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោសជនជាប់ចោទ:

១.១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២០ ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣០ (សាមសិប) ខែ



Scanned by CamScanner

១.២-ឈ្មោះ[redacted]ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣០ (សាមសិប) ខែ ។

១.៣-ឈ្មោះ[redacted]ភេទប្រុស អាយុ ២៨ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣៦ (សាមសិបប្រាំមួយ) ខែ ។

ពីបទៈ*រក្សាទុក និងផ្ទេរដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅភូមិត្រពាំងម្ទេស ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរួមមានៈ ម៉ូតូចំនួន ០១ គ្រឿង ម៉ាកស៊ីភីអរ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ ១ស៊ីខេ ៨៥៧០ លេខម៉ាស៊ីន អរស៊ី ១៧៨ អ៊ី ០៣០៨២៩១ លេខតួ អិលអេចខេស៊ី ១៧៨៩០៥៣០៨២៩១ តុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

៣-បង្គាប់ឲ្យអាជ្ញាធរមានសមត្ថកិច្ចស្វែងរកចាប់ខ្លួនជនជាប់ចោទឈ្មោះ[redacted]

៤-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ឈ្មោះ[redacted]និងកំបាំងមុខជនជាប់ចោទឈ្មោះ[redacted]។

បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ៕

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner